GC LiFE

# អត្ថប្រយោជន៍បន្ថែម
# គ្រុបមេឌីផ្លាស



## កម្មវត្ថុនៃការធានារ៉ាប់រង

ការចំណាយវេជ្ជសាស្ត្រលើថ្លៃសម្រាកព្យាបាល នៅមន្ទីរពេទ្យ និងការព្យាបាលពិគ្រោះជំងឺក្រៅ និងតម្លៃសេវារថយន្តគិលានសង្គ្រោះបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុ ក៏ដូចជាការធានារ៉ាប់រងលើការចំណាយវេជ្ជសាស្ត្របន្ថែមរបស់សមាជិកដែលត្រូវបានធានា។

## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុសមាជិកដែលត្រូវបានធានា | 3 - 64ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1ឆ្នាំ |

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| វិធីសាស្ត្របង់បុព្វលាភ | ដូចទៅនឹងផលិតផលមូលដ្ឋាន |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពេញ | ដូចទៅនឹងផលិតផលមូលដ្ឋាន |

## វិសាលភាពនៃការធានារ៉ាប់រង

ផលិតផលនេះផ្តល់នូវការធានាទៅលើការចំណាយវេជ្ជសាស្ត្រលើថ្លៃសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការព្យាបាលពិគ្រោះជំងឺក្រៅ និងតម្លៃសេវារថយន្តគិលានសង្គ្រោះបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុ ក៏ដូចជាការធានារ៉ាប់រងលើការចំណាយវេជ្ជសាស្ត្របន្ថែមដល់សមាជិកដែលត្រូវបានធានា។

## អត្ថប្រយោជន៍ធានារ៉ាប់រង

ក្រុមហ៊ុនធានារ៉ាប់រងនឹងរ៉ាប់រងលើការចំណាយជាក់ស្តែងសម្រាប់ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការព្យាបាលពិគ្រោះជំងឺក្រៅ និងតម្លៃសេវារថយន្តគិលានសង្គ្រោះបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុ និងរួមមានការធានារ៉ាប់រងលើការចំណាយវេជ្ជសាស្ត្របន្ថែមដូចមានបង្ហាញក្នុងតារាងអត្ថប្រយោជន៍ខាងក្រោម។

<table>
<tr><th colspan="3">តារាងអត្ថប្រយោជន៍</th></tr>
<tr><th>លេខរៀង</th><th>អត្ថប្រយោជន៍</th><th>កម្រិតចំនួនទឹកប្រាក់អត្ថប្រយោជន៍</th></tr>
<tr><td>1</td><td>ថ្លៃព្យាបាលសម្រាកនៅមន្ទីរពេទ្យដោយសារគ្រោះថ្នាក់ជាយថាហេតុ៖<br>១. តម្លៃសេវាបន្ទប់ គ្រែ និងអាហារ សម្រាប់ការសម្រាកព្យាបាលប្រចាំថ្ងៃនៅបន្ទប់ធម្មតា<br>២. តម្លៃសេវាបន្ទប់គ្រែ និងអាហារ សម្រាប់ការសម្រាកព្យាបាលនៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ (ICU)<br>៣. តម្លៃសេវាទូទៅរបស់មន្ទីរពេទ្យ / ការចំណាយផ្សេងៗទៀត<br>៤. អត្ថប្រយោជន៍សម្រាប់ការវះកាត់<br>៥. តម្លៃសេវាពិនិត្យដោយគ្រូពេទ្យនៅពេលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ<br>៦. អត្ថប្រយោជន៍ក្រោយពេលចេញមន្ទីរពេទ្យ</td><td rowspan="3">រហូតដល់ ១០%នៃទឹកប្រាក់ត្រូវបានធានារបស់ផលិតផលមូលដ្ឋាន ឬ$2,500 ដោយយកចំនួនណាមួយតិចជាងគេ</td></tr>
<tr><td>2</td><td>ថ្លៃព្យាបាលពិគ្រោះជំងឺក្រៅដោយសារគ្រោះថ្នាក់ជាយថាហេតុ៖<br>១. ថ្លៃសេវាពិគ្រោះជាមួយគ្រូពេទ្យ /គ្រូពេទ្យឯកទេស<br>២. ឱសថតាមវេជ្ជបញ្ជា និងការស្លៀកពាក់ និង<br>៣. នីតិវិធីធ្វើរោគវិនិច្ឆ័យតាមវេជ្ជបញ្ជា៖ កាំរស្មីអ៊ិច (X-ray) វាស់ចង្វាក់ចរន្តអគ្គិសនីបេះដូង (ECG) ការធ្វើតេស្តមេតាប៉ូលីសមូលដ្ឋាន ការពិនិត្យ និងធ្វើតេស្តមន្ទីរពិសោធន៍ ចតអេកូ ការឆ្លុះ (សុង) ស៊ីធីស្កែន (CT Scan) និង អ៊ឹមអរអាយ (MRI)។</td></tr>
<tr><td>3</td><td>ការរ៉ាប់រងការចំណាយផ្នែកវេជ្ជសាស្ត្របន្ថែម៖<br>១. អត្ថប្រយោជន៍ចំពោះការខូចខាតបង្កដោយគ្រោះថ្នាក់ជាយថាហេតុចំពោះធ្មេញធម្មជាតិ<br>២. ជំងឺគ្រុនឈាម ឬជំងឺគ្រុនចាញ់<br>៣. ការពុលចំណីអាហារ<br>៤. ពស់ ឬ សត្វល្អិត ឬ សត្វខាំ<br>៥. ការរងរបួសបង្កដោយការលេងកីឡា</td></tr>
<tr><td>4</td><td>តម្លៃសេវារថយន្តគិលានសង្គ្រោះបន្ទាន់ដោយសារគ្រោះថ្នាក់ជាយថាហេតុ</td><td>$300</td></tr>
</table>

បញ្ជាក់៖ រយៈពេលរង់ចាំត្រូវបានអនុវត្ត!

ចំណាំ៖ ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា សូមអានខ និងលក្ខខណ្ឌធានារ៉ាប់រង។

# ករណីមិនធានា

ក្រុមហ៊ុនមិនផ្តល់សំណងលើការព្យាបាលទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬ ដោយប្រយោលមកពីព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

១. គ្រោះថ្នាក់រូបរាងកាយ ឬមរណភាព បង្កដោយគ្រោះថ្នាក់ចរាចរណ៍ ក្នុងកំឡុងពេលបើកបរទោចក្រយានយន្ត (អ្នកបើកបរ ឬអ្នកដំណើរ) ដោយមិនពាក់មួកសុវត្ថិភាព វៀរលែងតែមានបញ្ជាក់ជាក់លាក់នៅក្នុងអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែម ឬ បុព្វលាភធានារ៉ាប់រងបន្ថែមត្រូវបានបង់។

២. ទទួលសេវាព្យាបាលដោយវិធីព្យាបាលក្រៅប្រព័ន្ធផ្សេងទៀតក្រៅពី គ្រូពេទ្យព្យាបាលដោយចលនាដែលមានអាជ្ញាប័ណ្ណ (Chiropractors) គ្រូពេទ្យព្យាបាលជំងឺទាក់ទងនឹងប្រព័ន្ធសាច់ដុំនិងឆ្អឹងដែលមានអាជ្ញាប័ណ្ណ (Osteopaths) គ្រូពេទ្យព្យាបាលអូមេអូផាសដែលមានអាជ្ញាប័ណ្ណ (Homeopaths) គ្រូពេទ្យព្យាបាលដោយប្រើម្ជុលវិទ្យាសាស្ត្រដែលមានអាជ្ញាប័ណ្ណ (Acupuncturists)។

៣. ការទាមទារសំណងណាមួយក្នុងកំឡុងពេលធ្វើដំណើរដែលធ្វើផ្ទុយពីដំបូន្មានវេជ្ជសាស្ត្រ។

៤. ស្ថានភាពវេជ្ជសាស្ត្រ ឬលក្ខខណ្ឌរូបរាងកាយ ដែលកើតមានឡើងដោយសារជំងឺគ្រុនឈាម ឬគ្រុនចាញ់ ក្នុងរយៈពេលរង់ចាំ លើកលែងករណីមានរបួសបង្កដោយគ្រោះថ្នាក់ជាយថាហេតុ។ ករណីនេះនឹងមិនត្រូវបានអនុវត្តឡើយ បន្ទាប់ពីការធានារ៉ាប់រងបានរយៈពេលសើសពីមួយឆ្នាំ។

៥. ការហោះហើរ ឬសកម្មភាពលើអាកាសនានា លើកលែងតែក្នុងករណីគឺជាអ្នកដំណើរក្នុងយន្តហោះ ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសដោយប្រើថាមពល ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ  (ពាក្យ “អ្នកដំណើរ” មិនរាប់បញ្ចូលសមាជិកនៃអាកាសយានិក ឬអ្នកបច្ចេកទេសធ្វើការនៅក្នុង ឬនៅលើយន្តហោះឡើយ)។

៦. ស្ថានភាពដែលមានពីមុនស្រាប់ ដែលបង្កដោយរបួស ឬជំងឺដែលសមាជិកត្រូវបានធានាបានទទួលការពិគ្រោះវេជ្ជសាស្ត្រ ការព្យាបាលផ្នែកវេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬសេវាកម្ម ឬ ការទទួលទានថ្នាំតាមវេជ្ជបញ្ជាក្នុងកំឡុងពេល១២ (ដប់ពីរ) ខែ មុនកាលបរិច្ឆេទសុពលភាពនៃការធានារ៉ាប់រងរបស់សមាជិកដែលត្រូវបានធានារូបនោះ។ គ្មានអត្ថប្រយោជន៍ធានារ៉ាប់រងណានឹងត្រូវបានផ្តល់ជូនស្របតាមអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែម និងកិច្ចសន្យាបន្ថែម ចំពោះស្ថានភាពដែលមានពីមុនស្រាប់ឡើយ វៀរលែងតែសមាជិកត្រូវបានធានារូបនោះស្ថិតក្រោមការធានារ៉ាប់រងជាប់មករហូតក្រោមបណ្ណសន្យារ៉ាប់រង ឬ ការធានារ៉ាប់រងលើការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងវះកាត់ជាក្រុមនៃម្ចាស់បណ្ណសន្យារ៉ាប់រងជាក្រុមនេះ បានយ៉ាងហោចណាស់១២ (ដប់ពីរ) ខែ ជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងមុន។

៧. ការព្យាបាលជំងឺផ្លូវចិត្ត របួសបង្កឡើងដោយសារជំងឺវិកលចរិក ឬការធ្វើទណ្ឌកម្មខ្លួនឯង ឬអំពើអត្តឃាត ការសម្រាកព្យាបាលខ្លួនឯង ឬការថែទាំដោយខ្លួនឯង ការថែទាំវេជ្ជសាស្ត្រជាពិសេស  ជំងឺឆ្លងដែលតម្រូវដោយច្បាប់ឱ្យដាក់ខ្លួននៅដាច់តែឯង ឬចត្តាឡីស័ក ជំងឺកាមរោគ សំណងដែលនៅក្នុងការយល់ឃើញរបស់ក្រុមហ៊ុនធានារ៉ាប់រងថាវាបានកើតឡើងដោយផ្ទាល់ ឬដោយប្រយោលពីជំងឺអេដស៍ ឬជំងឺទាំងឡាយណាដែលទាក់ទងនឹងមេរោគហ៊ីវ។

៨. ការត្រួតពិនិត្យរាងកាយជាប្រចាំ ការញៀនថ្នាំ ឬការញៀនសុរា សេវាកម្មផ្សេងៗទាក់ទងនិងការថែទាំនឹងព្យាបាលក្រអូមមាត់លើកលែងតែការវះកាត់របួសធ្មេញដែលបង្កឡើងដោយសារគ្រោះថ្នាក់ជាយថាហេតុ។

៩. កាត់ការវះកាត់ស្តាបនាឡើងវិញ ឬការវះកែសម្ផស្ស ការព្យាបាលសម្រស់ ឬការវះកាត់ដើម្បីបង្កើនសម្រស់ ការព្យាបាលភាពធាត់ ឬការសម្រកឬបង្កើនទំងន់ ឬការវះកាត់តាមចិត្តចង់ដោយមិនមែនការព្យាបាលផ្សេងៗ។